**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

## មតិផ្ដើមរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ថ្លែងក្នុងពិធីផ្សព្វផ្សាយអំពីខ្លឹមសាររដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និង សមត្ថកិច្ចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ

មុននឹងចូលដល់ប្រធានបទ ខ្ញុំសូមអនុញ្ញាតឧទ្ទេសនាមសមាសភាពគណៈប្រតិភូក្រុមប្រឹក្សា-ធម្មនុញ្ញ វត្តមានថ្ងៃនេះ មាន ......................................................................................

បេសកកម្មនេះ ក្រុមប្រឹក្សាធម្មនុញ្ញបានសហការជាមួយមូលនិធិ Konrad Adenauer Stiftung ដូចមាន Logoនៅខាងលើស្រាប់ ។

ជាបន្ត ខ្ញុំមានកិត្តិយសជម្រាបពីប្រវត្តិរដ្ឋធម្មនុញ្ញរបស់ប្រទេសយើងដូចតទៅ ប្រទេសកម្ពុជាចាប់ផ្ដើមមានរដ្ឋធម្មនុញ្ញតាំងពីឆ្នាំ១៩៤៧ មកម្ល៉េះ ហើយបានផ្លាស់ប្ដូរជាបន្តបន្ទាប់អស់ចំនួន ០៦ លើកមកហើយទៅតាមការផ្លាស់ប្ដូររបបនយោបាយមានដូចតទៅនេះ ÷

ទី១ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ពីឆ្នាំ១៩៤៧ ដល់ ឆ្នាំ១៩៧០ ត្រូវបានធ្វើវិសោធនកម្មចំនួន ១២ លើក និង ចែកចេញជា ១២ ជំពូក និង មាន ១២២ មាត្រា ។

ទី២ រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥ ចែកចេញជា ១១ជំពូក និង មាន ១២១ មាត្រា និង មានមាត្រាអវសានមួយផង ។

ទី៣ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ចែកចេញជា ១៦ជំពូក និង មាន ២១មាត្រា ។

ទី៤ រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨៩ ចែកចេញជា ១០ជំពូក និង មាន ៩៣មាត្រា ។

ទី៥ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ពីឆ្នាំ១៩៨៩ ដល់ ឆ្នាំ១៩៩៣ ចែកចេញជា ១០ជំពូក និង មាន ៩៣មាត្រា ។

ទី៦ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(ឆ្នាំ១៩៩៣) នៅក្នុងនីតិកាលទី១ នៃរដ្ឋសភា (១៩៩៣-១៩៩៨) រដ្ឋធម្មនុញ្ញនេះចែកចេញជា ១៤ជំពូក និង មាន ១៣៩មាត្រា ។ ឆ្លងពីរដ្ឋសភានីតិកាលទី ១ រហូតដល់រដ្ឋសភានីតិកាលទី ៤ បច្ចុប្បន្នយើងឃើញថាមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួន ៦ លើក ព្រមទាំងមានច្បាប់ធម្មនុញ្ញបន្ថែមមួយទៀត ដែលទាំងអស់ខាងលើនេះគឺសុទ្ធតែផ្អែកលើភាពចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា (សុភាសិតបារាំងមួយថា nécessité fait loi) ញុំាងឱ្យរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ ចែកជា ១៦ ជំពូក និង មាន ១៥៨មាត្រា ។

ផ្អែកតាមរបៀបវារៈព្រឹកនេះ យើងលើកយករដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញមកធ្វើជាប្រធានបទសម្រាប់ស្វែងយល់ ដោយមានឯកឧត្តម **ម៉ែន ឌុល** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកឧទ្ទេសនាម ។

ខ្ញុំមានកិត្តិយស ជម្រាបជូនអំពីស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលមួយ ឯករាជ្យ និង អព្យាក្រឹត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និង ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ ចាប់ផ្តើមបំពេញការងាររបស់ខ្លួនពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ១៩៩៨ នៅអគារ "ស" ក្នុងបរិវេណវិមានរដ្ឋចំការមន។

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពព្រមទាំងមានសិទ្ធិពិនិត្យ និង សម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ក្រុមប្រឹក្សាធម្មនុញ្ញ ថ្វាយមតិព្រះមហាក្សត្រចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើការសើរើនិងវិសោធនកម្មរដ្ឋធម្មនុញ្ញ។ ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់ ក្នុងកាលៈទេសៈប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ឬ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចមិនអាចសុំកែប្រែបានជាដាច់ខាត ។

ខ្ញុំសូមគូសបញ្ជាក់ថា ច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។ ការអនុម័តទាំងឡាយណារបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចអំពីមោឃភាពនេះ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ការបង្កើតស្ថាប័ននេះឡើង គឺដើម្បីរួមចំណែកក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សការគោរពសិទ្ធិមនុស្ស ការកសាងនីតិរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជានៃយើង។ ម្យ៉ាងទៀត បច្ចុប្បន្ននេះក្រុមប្រឹក្សាធម្មនុញ្ញ ក៏បានរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំសង្ឃឹមថា ពិធីផ្សព្វផ្សាយក្នុងថ្ងៃនេះ អាចចាត់ទុកជាវគ្គរៀនសូត្រខ្លីមួយដែលអាចនាំឱ្យមានការយល់ដឹងមួយកម្រិតថែមទៀតអំពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ និងអំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមគ្នាគោរព និង ប្រតិបត្តិតាមដូចបទប្បញ្ញត្តិនៃវាក្យខណ្ឌទី១ នៃមាត្រា៤៩ នៃរដ្ឋធម្មនុញ្ញចែងថា : ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និង គោរពច្បាប់ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្វាយព្រះពរ និង ជូនពរដល់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលចូលរួម សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

បន្តទៅនេះ ខ្ញុំសូមអនុញ្ញាតដឹកនាំកម្មវិធី ដោយសូមអញ្ជើញឯកឧត្តម **ម៉ែន ផុល** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើបទឧទ្ទេសនាមពីតុគណៈអធិបតី។

**សូមអរគុណ**